ត្រូវប្រគល់ជូនវិញ បន្ទាប់មកលិខិតបញ្ជាក់មរណៈភាពជំនួស រួមបញ្ចូលទាំងមូលហេតុនៃមរណៈភាព នឹងអាចស្នើសុំបានដោយឥតគិតថ្លៃ ។

## ការផ្សព្វផ្សាយព័ត៌មាន

នៅពេលមានការស្លាប់ភ្លាមៗ ព័ត៌មាននឹងត្រូវទទួលបានការចាប់អារម្មណ៍ ដោយរាយការណ៍អំពីហេតុការណ៍ដែលបានកើតឡើង ។ អ្នកនឹងមិនត្រូវបង្គាប់ឱ្យនិយាយនៅពេលផ្សព្វផ្សាយព័ត៌មានទេ ។ អ្នកមានសិទ្ធិស្នើសុំភាពជាឯកជន សំរាប់ក្រុមគ្រួសាររបស់អ្នកនៅពេលនេះបាន ។

## ការគាំទ្រ

ផ្នែកគាំទ្រជនរងគ្រោះ ផ្តល់ការគាំទ្រ ២៤ ម៉ោង ទាំងផ្លូវប្រតិបត្តិ និងផ្លូវអារម្មណ៍ ការតស៊ូមតិផ្ទាល់ខ្លួន ព្រមទាំងព័ត៌មានជូនប្រជាពលរដ្ឋទាំងអស់ ដែលរងគ្រោះដោយបទឧក្រិដ្ឋ និងរងរបួស នៅទូទាំងប្រទេសញូវហ្សេឡែន ។

ទំនាក់ទំនងមកកាន់បុស្តិ៍ប៉ូលីសដែលស្ថិតនៅក្នុងមូលដ្ឋានរបស់អ្នក និងស្នើសុំការគាំទ្រជនរងគ្រោះ សូមទូរស័ព្ទមកកាន់លេខ 0800 ផ្នែកជនរងគ្រោះ (0800 842 846) ឬ បើកមើលវេបសាយ www.victimsupport.org.nz



## លេខទូរស័ព្ទទំនាក់ទំនងសំខាន់ៗ

**ផ្នែកគាំទ្រជនរងគ្រោះ** :ទំនាក់ទំនងមកកាន់បុស្តិ៍ប៉ូលីសដែលស្ថិតនៅក្នុងមូលដ្ឋានរបស់ អ្នក និងស្នើសុំការគាំទ្រជនរងគ្រោះ សូមទូរស័ព្ទមកកាន់លេខ 0800 ផ្នែកជនរងគ្រោះ (0800 842 846) ឬ បើកមើលវេបសាយ www.victimsupport.org.nz

**ប៉ូលីសញូវហ្សេឡែន** : សូមបើកមើលវេបសាយរបស់រដ្ឋាភិបាលត្រង់ទំព័រស សំរាប់ព័ត៌មានទំនាក់ទំនងលំអិតមកកាន់បុស្តិ៍ប៉ូលីស ដែលស្ថិតនៅក្នុងមូលដ្ឋានរបស់អ្នក សូមបើកមើលវេបសាយ www.police.govt.nz នៅក្រោមប៉ូលីសមូលដ្ឋាន ។

## សេវាវិភាគសាកសពញូវហ្សេឡែន

| | |
|---|---|
| អកឡែន | (09) 916 9419 |
| គ្រីស្តឆឺច | (03) 353 0444 |
| ឌូណេឌីន | (03) 470 1147 |
| ហាមីលតុន | (07) 834 1756 |
| ហាស្ទីងស៍ | (06) 870 3116 |
| ផាលមឺសស្តុនខាងជើង | (06) 350 0083 |
| រ៉ូតួរូ | (07) 343 1021 |
| វែលលីងតុន | (04) 910 4487 |
| វ៉ាងហ្គារី | (09) 430 430 |
| ការិយាល័យជាតិ | (04) 910 4487 |
| ការិយាល័យប្រធានអ្នកធ្វើសពវិភាគ | (09) 916 9151 |

www.justice.govt.nz/coroners

© Crown Copyright 2010

CORONIAL SERVICES OF NEW ZEALAND

Purongo O te Ao Kakarauri

Item code: JUSCS0017



# ៤៨ ម៉ោងដំបូង

## អ្វីដែលត្រូវរំពឹង ក្រោយពេលស្លាប់ភ្លាម

# ការស្លាប់ភ្លាមៗ

ការស្លាប់ភ្លាមៗ ដែលត្រូវរាយការណ៍គឺជាការស្លាប់៖

- ដែលមិនដឹងអំពីមូលហេតុថាធ្វើអត្តឃាត ខុសពីធម្មតា ឬអំពើហឹង្សាទេ
- នៅពេលវេជ្ជបណ្ឌិតមិនអាចផ្តល់លិខិតបញ្ជាក់អំពីមូលហេតុបណ្តាលឱ្យស្លាប់បាន
- កើតឡើងអំឡុងពេល ឬបណ្តាលមកពីការប្រើប្រាស់ឱសថ ការវះកាត់ ឬទម្រង់ការថែ្ទកទន្តិត
- កើតឡើងខណៈពេល ឬបណ្តាលមកពីការសម្រាលកូនរបស់ស្ត្រី និង
- កើតឡើងខណៈពេលដែលការស្លាប់ ស្ថិតនៅក្នុងការថែទាំ និងមានសិទ្ធិព្យាបាលជាផ្លូវការ ។

ប៉ូលិសនឹងរាយការណ៍អំពីការស្លាប់ទាំងនេះមកកាន់អ្នកធ្វើសពវិភាគ ។

## តើនឹងមានអ្វីកើតឡើង រយៈពេល ៤៨ម៉ោងក្រោយមកទៀត?

អ្នកដែលស្លាប់ នឹងត្រូវយកទៅកាន់កន្លែងដែលមានសុវត្ថិភាព ( ដូចជា សាលដាក់សពរបស់មន្ទីរពេទ្យ ឬឃាបនដ្ឋានជាដើម) រហូតដល់អ្នកធ្វើសពវិភាគធ្វើការសម្រេចចិត្តថា តើត្រូវពិនិត្យសាកសពក្រោយពេលស្លាប់ដែរឬទេ ។

តំណាងរបស់អ្នកធ្វើសពវិភាគ ដែលអាចជាមន្ត្រីប៉ូលិស អាចទំនាក់ទំនងអ្នកដើម្បីសាកសួរព័ត៌មានបន្ថែម អំពីព្រឹត្តិការណ៍ដែលកើតឡើងនៅពេលស្លាប់ ។

អ្នកធ្វើសពវិភាគ នឹងត្រូវសម្រេចចិត្តថាតើ ត្រូវធ្វើការស៊ើបអង្កេតចំពោះការស្លាប់នោះដែរឬទេ ។

## ការកំណត់អត្តសញ្ញាណ

ការកំណត់អត្តសញ្ញាណជាផ្លូវការមួយ នឹងត្រូវធ្វើឡើងចំពោះអ្នកដែលស្លាប់ ដើម្បីឱ្យគេអាចបញ្ជាក់អំពីអត្តសញ្ញាណនោះបាន ។ បុគ្គលិកសុខាភិបាលអាចធ្វើកិច្ចការ

នេះបាន ប្រសិនបើមានវត្តមាននៅពេលស្លាប់ ឬប្រសិនបើបុគ្គលិកដឹងអំពីព័ត៌មានរបស់អ្នកដែលស្លាប់នោះ ។ សម្ភារផ្ទាល់ខ្លួន/របាយការណ៍ទន្តិត/ឌុណៅ អាចយកមកប្រើប្រាស់ ដើម្បីជួយសម្រួលដល់ការកំណត់អត្តសញ្ញាណបាន ប្រសិនបើចាំបាច់ ។ សេចក្តីថ្លែងទុកជាសាក្សី នឹងត្រូវចុះហត្ថលេខាដោយបុគ្គលដែលធ្វើការកំណត់អត្តសញ្ញាណនោះ ។



វាជាការសំខាន់ណាស់ដែលការកំណត់អត្តសញ្ញាណ ត្រូវធ្វើឡើងឱ្យបានឆាប់ ដើម្បីឱ្យញាតិសន្តានរបស់សាកសពលើកក្រោយៗ អាចទទួលការណែនាំអំពីការស្លាប់នេះបាន ។

## ការពិនិត្យសាកសពក្រោយពេលស្លាប់

ជួនកាល ការពិនិត្យសាកសពក្រោយពេលស្លាប់ ត្រូវបានគេហៅថាការវះកាត់ពិនិត្យសាកសព ។ ការពិនិត្យនេះ ត្រូវធ្វើឡើងយ៉ាងហ្មត់ចត់ ដោយពិនិត្យទាំងផ្នែកខាងក្នុង និងផ្នែកខាងក្រៅសាកសព ដោយគ្រូពេទ្យដែលមានជំនាញ ដែលត្រូវបានគេស្គាល់ថារោគសាស្ត្រិន ហើយជាធម្មតាធ្វើឡើងនៅកន្លែងរក្សាសាកសពរបស់មន្ទីរពេទ្យ ។ មិនមែនគ្រប់មន្ទីរពេទ្យទាំងអស់ សុទ្ធតែមានកន្លែងរក្សាសាកសព សំរាប់ធ្វើការពិនិត្យសាកសពក្រោយពេលស្លាប់នោះទេ ដូច្នេះហើយអ្នកដែលស្លាប់នោះ អាចត្រូវបានដឹកជញ្ជូនទៅកាន់ទីក្រុងធំ ដែលនៅជិតមន្ទីរពេទ្យនោះ ។

កង្វល់របស់ក្រុមគ្រួសារ ត្រូវបានគោរព ហើយអ្នកដែលស្លាប់ត្រូវបានផ្តល់ការគោរព និងភាពថ្លៃថ្នូរយ៉ាងខ្ពង់ខ្ពស់បំផុត នៅក្នុងដំណើរការវិភាគសាកសពទាំងស្រុង ។

## ការជំទាស់ទៅនឹងការពិនិត្យសាកសពក្រោយពេលស្លាប់

ក្រុមគ្រួសារផ្ទាល់ មានសិទ្ធិជំទាស់ទៅនឹងការពិនិត្យសាកសពក្រោយពេលស្លាប់បាន លើកលែងតែ៖

- ការស្លាប់នោះបណ្តាលមកពីទង្វើដែលបង្កើតជាការប្រព្រឹត្តិបទឧក្រិដ្ឋ **ឬ**
- ច្បាប់របស់ប្រទេសញូវហ្សឺលែន ឬច្បាប់អន្តរជាតិតម្រូវឱ្យមានការអនុវត្តពិនិត្យសាកសពក្រោយពេលស្លាប់ **ឬ**
- ប្រសិនបើអ្នកធ្វើសពវិភាគ បានពិនិត្យសាកសពដោយផ្ទាល់ ក្រោយពេលស្លាប់ ភ្លាមព្រោះការពន្យារពេលនឹង ឬអាចកំណត់អំពីសមត្ថភាពរបស់រោគសាស្ត្រិន ក្នុងការកំណត់អំពីមូលហេតុនៃការស្លាប់នោះ ។

រាល់ការជំទាស់ត្រូវប្រាប់អ្នកធ្វើសពវិភាគក្នុងរយៈពេល **24ម៉ោង** ក្រោយពីទទួលដំណឹងអំពីការសម្រេចរបស់អ្នកធ្វើសពវិភាគ ។ ក្រុមគ្រួសារ គួរប្រាប់អ្នកធ្វើសពវិភាគអំពីមូលហេតុរាល់ការជំទាស់ ដោយទូរស័ព្ទមកកាន់លេខ ដែលអ្នកធ្វើសពវិភាគបានផ្តល់ជូននៅពេលប្រាប់អំពីការសម្រេចចិត្តពីដំបូង ។ ប្រសិនបើអ្នកមានចម្ងល់ សូមទាក់ទងមកកាន់ប៉ូលីស ឬផ្នែកគាំទ្រជនរងគ្រោះ ។

## តម្រូវការផ្នែកវប្បធម៌របស់អ្នក

រាល់ការប្រឹងប្រែង នឹងត្រូវធ្វើឡើងដើម្បីទទួលស្គាល់ និងគោរពចំពោះជំនឿសាសនា និងជំនឿវប្បធម៌ ដែលមាននៅប្រទេសញូវហ្សឺលែន ហើយតម្រូវការផ្ទាល់ខ្លួនរបស់អ្នក ត្រូវជូនដំណឹងឱ្យបានច្បាស់លាស់ មកកាន់តំណាងអ្នកធ្វើសពវិភាគ ឱ្យបានឆាប់បំផុត ។

## តើត្រូវចំនាយពេលយូរប៉ុណ្ណា?

រាល់ការស្លាប់គឺមានលក្ខណៈខុសៗគ្នា ហើយការស៊ើបអង្កេតត្រូវចំនាយពេលខ្លះ ។ តំណាងអ្នកធ្វើសពវិភាគ ដែលអាចជាមន្ត្រីប៉ូលីស នឹងទាក់ទងអ្នក ដើម្បីផ្តល់ព័ត៌មានដល់អ្នកអំពីអ្វីដែលនឹងកើតឡើង ។ ប្រសិនបើអ្នកមានចម្ងល់ សូមទាក់ទងមកកាន់សេវាវិភាគសាកសពញូវហ្សឺលែន ឬមន្ត្រីស៊ើបអង្កេតពីប៉ុស្តិ៍ប៉ូលីស ។

## ទ្រព្យសម្បត្តិផ្ទាល់ខ្លួន

ប៉ូលីស ឬបុគ្គលិកសុខាភិបាល អាចប្រគល់សម្ភារផ្ទាល់ខ្លួនសាកសព ( ដូចជា គ្រឿងអលង្ការ កាបូបលុយ ឬសំលៀកបំពាក់ ) នៅពេលស្លាប់បាន ។ ម្យ៉ាងទៀត ប៉ូលីស ឬអ្នករៀបចំបុណ្យសព អាចប្រគល់សម្ភារទាំងនេះជូនក្រុមគ្រួសារ នៅថ្ងៃបន្ទាប់បាន ។

សម្ភារមួយចំនួន អាចចាំបាច់ត្រូវរក្សាទុក ដើម្បីធ្វើការស៊ើបអង្កេតតាមនីតិវេជ្ជវិទ្យា ឬសំរាប់ការស៊ើបអង្កេតដែលកំពុងបន្តរបស់ប៉ូលីស ហើយនឹងត្រូវប្រគល់ជូនក្រុមគ្រួសារនៅថ្ងៃក្រោយវិញ ។

## ការទទួលលិខិតបញ្ជាក់មរណៈភាព

ប្រសិនបើការស្លាប់នោះមានលិខិតបញ្ជាក់កំណើត មរណៈភាព និងអាពាហ៍ពិពាហ៍ គេអាចស្នើសុំលិខិតបញ្ជាក់មរណៈភាពបាន ។ ប្រសិនបើត្រូវធ្វើការស៊ើបអង្កេត លិខិតបញ្ជាក់នេះ អាចជាលិខិតបញ្ជាក់បណ្តោះអាសន្ន ប៉ុណ្ណោះ ដែលបញ្ជាក់ "ទាក់ទងនឹងលទ្ធផល របស់អ្នកធ្វើសពវិភាគ" នៅក្នុងកន្លែងមូលហេតុនៃមរណៈភាព ។ មិនមាន ថ្លៃឈ្នួល ត្រូវចំនាយ ទៅលើការចុះបញ្ជី កំណើត មរណៈភាព និងអាពាហ៍ពិពាហ៍ទេ ប៉ុន្តែត្រូវយកថ្លៃឈ្នួល នៅពេលអ្នកស្នើសុំលិខិតបញ្ជាក់មរណៈភាព ។

លិខិតបញ្ជាក់កំណើត មរណៈភាព និងអាពាហ៍ពិពាហ៍ នឹងកែតម្រូវមូលហេតុនៃ មរណៈភាព ដែលមានលទ្ធផលរបស់អ្នកធ្វើសពវិភាគ និងលិខិតបញ្ជាក់មរណៈភាពបណ្តោះអាសន្ន នឹង

